# បទអប់រំខ្លី

## ស្តីអំពី: "អានិសង្សមេត្តាធម៌"



នៅក្នុងពិភពលោកទាំងមូលនេះប្រសិនបើ មិនមានការអាណិតអាសូរដល់គ្នាទេ គឺគ្មានការស្រឡាញ់កើតឡើងដែរ គឺមានតែការកាប់សម្លាប់គ្នា មិនមានការញញើតសោះឡើយ។

ជីវិតនេះដែលបានឧប្បត្តិកើតឡើង វាអា-

ស្រ័យបុណ្យកុសលដែលយើងបានសន្សំ ឬក៏បាន
កសាងមកទើបឲ្យបានកើតមក ជាមនុស្សនេះ
ឡើង, សព្វសត្វទាំងអស់ ដែលកើតមកក្នុងវដ្ដ-
សង្សារវិលវល់គ្មានទីបញ្ចប់ ក៏ព្រោះតែអវិជ្ជាបិទ
បាំងមិនអាចឲ្យមើលឃើញបាន ។សេចក្ដីល្អដែល
បានបំពេញមក យើងអាចមើលឃើញការប្រព្រឹត្ត
ល្អបាន ទាល់តែយើងហ្នឹងចូលទៅអាស្រ័យសេព
ជាមួយសេចក្ដីល្អរបស់យើងផងដែរ ទើបឃើញ
ការប្រព្រឹត្តល្អឬអាក្រក់របស់ខ្លួនបាន ។

ជីវិតរស់នៅជាមួយគ្នា មានការស្រឡាញ់
រាប់អានគ្នាបាន ទាល់តែយើងមានធម៌មេត្តាដូចគ្នា
បើរស់នៅគ្មានមេត្តាសម្រាប់ការពារពីខាងក្រៅទេ
នោះ ប្រហែលជាសម្លាប់គ្នាឯង មិនស្គាល់ថាអ្វីជា
ល្អអ្វីជាអាក្រក់ឡើយ ។

ក៏ឯមេត្តានោះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់

សម្តែងក្នុង**បដិសម្ភិទាមគ្គ ខុទ្ទកនិកាយ បិដក** (លេខ៧១,ទំព័រ៩៦) ជាអានិសង្សនៃការមានមេត្តាធម៌មាន១១ប្រការគឺ ។

**១.សុខំ សុបតិ** បុគ្គលប្រកបដោយមេត្តារមែងដេកលក់ជាសុខស្រួលល្អ, ចំណែកជនដទៃដែលមិនមានមេត្តារមែងដេកលក់អាក្រក់ គឺដេកបម្រះននៀលស្រមុកលាន់ឮ សំឡេងអាក្រក់ផ្សេងៗ បុគ្គលប្រកបដោយមេត្តា មិនដូច្នោះឡើយដេកលក់ជាសុខស្រួលហាក់ដូចជា ចូលកាន់សមាបត្តិគ្មានសេចក្តីទុក្ខកង្វល់ឡើយ ។

**២.សុខំ បដិពុជ្ឈតិ** បុគ្គលប្រកបដោយមេត្តា រមែងភ្ញាក់អំពីដំណេក ក៏ជាសុខស្រួលល្អ, ចំណែកជនដទៃ រមែងភ្ញាក់ពីដំណេកដោយអាក្រក់ គឺធ្វើសំឡេងថ្ងូរគ្រហឹមពើតពត់កាយបម្រះននៀលកាយផ្សេងៗ, អ្នកប្រកបដោយមេត្តា

មិនដូច្នោះឡើយ រមែងភ្ញាក់ឡើងជាសុខស្រួលល្អ ប្រៀបដូចជាផ្កាឈូករីកពេលព្រឹក ។

**៣.ន បាបកំ សុបិនំ បស្សតិ** អ្នកប្រកបដោយមេត្តាកាលនឹងដេកលក់ទៅ មិនបានយល់សប្តិឃើញអាក្រក់ឡើយ គឺយល់សប្តិឃើញតែល្អៗឃើញដូចជា បានថ្វាយបង្គំចេតិយ ហាក់ដូចជាបានបូជាព្រះរតនត្រៃហាក់ដូចជាបានស្តាប់ធម៌ជាដើម, ចំណែកជនដទៃ ដែលមិនមានមេត្តារមែងយល់សប្តិឃើញ ហាក់ដូចជាចោរដេញកាប់ស្ទើរតែរត់មិនរួច ដោយសារបុគ្គលនោះឯង គ្មានធម៌ គឺមេត្តាសេចក្តីអាណិតដល់សត្វ ។

**៤.មនុស្សានំ បិយោ ហោតិ** អ្នកប្រកបដោយមេត្តា រមែងជាទីស្រឡាញ់ ជាទីគាប់ចិត្តនៃមនុស្សទាំងឡាយ ប្រៀបដូចកែវមុត្តាហារសម្រាប់ពាក់នឹងដើមទ្រូង និងកម្រងផ្កាសម្រាប់ប្រដាប់

តាក់តែងសីសៈ(ក្បាល) ។

**៥.អមនុស្សានំ បិយោ ហោតិ** អ្នកប្រកបដោយមេត្តា រមែងជាទីស្រឡាញ់ ជាទីគាប់ចិត្តនៃអមនុស្សទាំងឡាយ មានទេវតាជាដើម ។

**៦.ទេវតា រក្ខន្តិ** ពួកទេវតាទាំងឡាយ តែងថែរក្សាបុគ្គលដែលប្រកបដោយមេត្តា ប្រៀបដូចជាមាតាបិតារក្សានូវកូនដូច្នោះឯង ។

**៧.នាស្ស អគ្គិ វា វិសំ វា សត្ថំ វា កម្បតិ** បុគ្គលប្រកបដោយមេត្តា មិនញាប់ញ័រមិនធេះរលាក ឬក្តៅក្រហាយដោយភ្លើង មិនបានស្លាប់វិនាសដោយថ្នាំពិសបំពុល មិនបានមុតដោយគ្រឿងសស្ត្រាវុធផ្សេងៗ ។

ដូចជារឿងមេគោ កំពុងតែបំបៅដោះកូន មាននាយព្រានម្នាក់ គិតនឹងចាក់មេគោនោះ

ដោយលំពែង ហើយក៏ពួយលំពែងមានដងវែង សំដៅទៅមេគោនោះ ។ ឯលំពែងនោះ ស្ទុះទៅត្រូវសរីរៈមេគោនោះ តែមូរមុខប្រៀបដូចស្លឹកត្នោតដែលគេមូរ មិនបានមុតមេគោនោះឡើយ អំពើនោះ មិនបានប្រព្រឹត្តទៅដោយកម្លាំងឧបចារសមាធិ(ព្រំដែននៃការតម្កល់ចិត្ត) ឬអប្បនាសមាធិ (ការតម្កល់ចិត្តឲ្យតាំងនៅស៊ប់មាំក្នុងឈាន) ឡើយ ប្រព្រឹត្តទៅដោយអំណាចនៃសេចក្តីស្រឡាញ់ដ៏មានកម្លាំងក្នុងកូនគោប៉ុណ្ណោះឯង, មេត្តាមានអានុភាពធំយ៉ាងនេះ ។

**៨.តុវដំ ចិត្តំ សមាធិយតិ** ចិត្តរបស់អ្នកប្រកបដោយមេត្តា រមែងតាំងនៅខ្ជាប់ខ្ជួនល្អដោយឆាប់រហ័ស មិនបានយឺតយូរឡើយ ។

**៩.មុខវណ្ណោ វិប្បសីទតិ** អ្នកប្រកបដោយមេត្តា រមែងមានមុខស្រស់បស់ ប្រៀបដូចផ្លែត្នោត

ទុំដែលទើបនឹងជ្រុះចាកទង។

**១០.អសម្មូឡ្ហោ កាលំ ករោតិ** អ្នកប្រកបដោយមេត្តា មិនបានធ្វើមរណកាលដោយសេចក្តីវង្វេង គឺគ្មានសេចក្តីវង្វេងហើយស្លាប់ទេ គឺថាស្លាប់ដូចគេដេកលក់ស្រួល ។

១១.**ឧត្តរឹ អប្បដិវិជ្ឈន្តោ ព្រហ្មលោកោ ហោតិ** អ្នកប្រកបដោយមេត្តា ទុកជាមិនបានត្រាស់ដឹងនូវគុណធម៌ដ៏ខ្ពង់ខ្ពស់ជាងមេត្តាសមាបត្តិនោះក៏ដោយលុះច្យុតអំពីមនុស្សលោកនេះទៅ ក៏គង់តែបានទៅកើតក្នុងព្រហ្មលោកពុំខានឡើយ ។

ម្យ៉ាងទៀត ការផ្សាយមេត្តានោះ មាន៣ប្រការគឺ៖

**១.អនោធិសោ ផរណា** ផ្សាយទៅដោយមិនមានចំណែកជាស្រីជាប្រុសជាដើម ។

**២.ឱធិសោ ផរណា** ផ្សាយទៅដោយចំណែកជាស្រីជាប្រុសជាដើម ។

**៣.អនោធិសោ ទិសា ផរណា** ផ្សាយទៅកាន់ទិសទាំងពួង ដោយមិនគិតថាកន្លែងណាឡើយ ឲ្យតែកន្លែងនោះមានសេចក្តីទុក្ខរបស់សត្វគឺផ្សាយទៅដើម្បីឲ្យគ្នាបាននូវសេចក្តីសុខ។

សេចក្តីនៃការរៀបរាប់ អំពីអានិសង្សមេត្តាជាផ្លូវដ៏បរិសុទ្ធរបស់បុគ្គល ដែលមានព្យាបាទច្រើន ឲ្យមកជាមិនមានព្យាបាទវិញ ។

# រៀបរៀងចងក្រងដោយសាមណេរ

## សុវណ្ណប្បញ្ញោ **ស្វាត់ សុឆើត**

## ឧបត្ថម្ភសាចារ្យ **លីប៊ុនលីន**

## ចានពិនិត្យនិងផ្ទៀងផ្ទាត់

## កែសម្រួលសំណៅដេះ

## លោកគ្រូព្រះមហាធម្មាលង្ការោ **ចាន់ សុជន**

ប្រធានកម្មវិធីផាធីសំឡេងព្រះធម៌វត្តប្រាសាទស្រះកណ្តាល

(ខ្ពស់)

## **ចានពិនិត្យ និងឯកភាព**

*ធ្វើនៅវត្តប្រាសាទស្រះកណ្ដាល(ខ្ពស់) ថ្ងៃ៨រោចខែបឋមាសាឍព.ស២៥៥៩ ត្រូវនឹងថ្ងៃពុធទី០៨ខែកក្កដាឆ្នាំ២០១៥*